# "ជាតក" បង្ហាញតាមចម្លាក់និងគំនូរ

"ជាតក" ជារឿងដែលនិយាយពីជាតិទាំងឡាយរបស់ព្រះពោធិសត្វ មុនជាតិដែលព្រះអង្គបានត្រាស់ជាព្រះពុទ្ធ។[១] រឿងនេះមានប្រភពដើមនៅក្នុងគម្ពីរ "សុត្តន្តបិដក" ឬ "ព្រះសូត្របិដក"។ សុត្តន្តបិដកមានចែកជាច្រើនក្រុមទៀតហៅថា "និកាយ"។ ក្នុងបណ្ដានិកាយទាំងនោះ មាននិកាយមួយឈ្មោះថា "ខុទ្ទកនិកាយ" ដែលចែកជារឿងមួយពួកៗទៀតហៅថា "និបាត"។ និបាតទាំងអស់មានចំនួន២២ ហើយក្នុងនិបាតទាំង២២នោះមានជាតកសរុបទាំងអស់ចំនួន៥៥០។[២] តួលេខ ៥៥០នេះគ្រាន់តែជាចំនួនប្រហាក់ប្រហែល ឬតួលេខនិម្មិតឡើងប៉ុណ្ណោះ ព្រោះបើរាប់ជាតកទាំងអស់ក្នុងគម្ពីរបាលី (ព្រះត្រៃបិដក) ក្ដី ឬ សៀវភៅដែលលោកសាស្ត្រាចារ្យ *E.B.Cowell* បកប្រែហើយបោះពុម្ពផ្សាយជាភាសាអង់គ្លេសក្ដី គឺមានតែ៥៤៧ប៉ុណ្ណោះ។[៣] ក្នុងចំណោមជាតកទាំង៥៤៧នេះទៀតសោត គឺជួនកាលមានរឿងខ្លះដូចគ្នា ឬក៏រឿងពីរបីបញ្ចូលគ្នាតែមួយកើតចេញជារឿងថ្មីមួយទៀត។[៤] តាមពិតទៅ ព្រះត្រៃបិដកអធិប្បាយអំពីជាតកជាគាថាខ្លីៗប៉ុណ្ណោះ ហើយពិបាកយល់ណាស់។ គាថាទាំងនោះទៀតសោត ជួនកាលជាបញ្ហា ជាសុភាសិត ជានិទាន ឬជាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធចំពោះសាវ័កណាមួយរបស់ព្រះអង្គ ឬក៏ជាការប្រៀបធៀបនូវទង្វើរបស់ពុទ្ធសាសនិកណាម្នាក់ទៅនឹងតួអង្គក្នុងរឿងជាតក ឬពេលខ្លះជាដើមបទ ឬសេចក្ដីសង្ខេបរបស់ជាតកនោះតែម្ដង។ ម្ល៉ោះហើយ ប្រសិនបើចង់ដឹងអំពីរឿងជាតកពេញលេញ និងងាយយល់នោះ គឺត្រូវមើលនៅក្នុងគម្ពីរ "អដ្ឋកថា" ដែលជាគម្ពីរអធិប្បាយសម្រាយចេញពីគម្ពីរព្រះត្រៃបិដក។

---

[១] សំដៅលើ "ព្រះពុទ្ធគោតម" ដែលពុទ្ធសាសនិកជនកំពុងគោរពប្រណិបត្តិសព្វថ្ងៃ។

[២] សូមអាន Rhys Davids 1880: i និង Cowell 2005: xxiii។

[៣] ក្នុងគម្ពីរព្រះត្រៃបិដកមិនមានលេខរៀងពី១ដល់៥៤៧នោះទេ តែមានលេខរៀងតាមវគ្គ ដែលវគ្គភាគច្រើនមានលេខរៀងចាប់ពី១ដល់១០ប៉ុណ្ណោះ។ ម្ល៉ោះហើយដើម្បីងាយយល់ ខ្ញុំដាក់លេខរៀងតាមលំដាប់ពី១ដល់៥៤៧ដូចក្នុងសៀវភៅរបស់លោកសាស្ត្រាចារ្យ Cowell ។ សូមអានបន្ថែមគម្ពីរសុត្តន្តបិដក ផ្នែកខុទ្ទកនិកាយ ភាគទី៥៨ដល់៦៣។

[៤] Horner 1993: viii.

អត្ថបទដោយ៖ សាន ផល្លា

ជាតកជាគម្ពីរពុទ្ធសាសនាធំមួយដែលប្រមូលផ្តុំដោយរឿងចាស់ៗជាច្រើនបញ្ចូលគ្នារួមមានរឿងព្រេង និងរឿងទេពកថាជាដើមៗ គេពុំដឹងច្បាស់ថា តើរឿងនេះកើតឡើងយ៉ាងដូចម្តេចឡើយៗ ប៉ុន្តែបើតាមពុទ្ធសាសនិកជនជឿពីបរមបុរាណមកថា នៅពេលដែលជួបរឿងរ៉ាវពិបាកដោះស្រាយក្នុងឱកាសយាងទេសនាប្រោសសត្វក្រោយត្រាស់ដឹង ព្រះពុទ្ធគោតមតែងអត្ថាធិប្បាយពន្យល់ហេតុការណ៍ដែលកើតឡើងនាពេលនោះ ដោយនិទានរឿងអតីតកំណើតរបស់ព្រះអង្គកាលនៅជាពោធិសត្វ ដែលស្រដៀងទៅនឹងព្រឹត្តិការណ៍នោះៗ តាមរយៈរឿងនិទាននោះ ព្រះពុទ្ធពោលសរសើរនូវសេចក្តីប្រតិបត្តិល្អរបស់តួអង្គព្រះពោធិសត្វក្នុងរឿង ហើយក៏យកជាឧទាហរណ៍ដើម្បីទូន្មានសាវកទាំងឡាយពីទង្វើជាសីលធម៌, មេត្តា, ករុណា.....ៗ គេជឿថា រឿងកំណើតព្រះពោធិសត្វដែលព្រះពុទ្ធនិទានឡើងទាំងអស់នោះ ត្រូវសាវករបស់ព្រះអង្គនិទានតៗគ្នា ហើយក្រោយពេលព្រះអង្គចូលព្រះបរិនិព្វាន រឿងទាំងនោះត្រូវគេប្រមូលបាន៥៥០ ហើយនិពន្ធចងក្រងជាគម្ពីរបាលីតែមួយហៅថា "គម្ពីរជាតក៥៥០ ឬកំណើត៥៥០" ក្នុងពេលធ្វើ "សង្គាយនានៅបត្ន" ដែលប្រារព្ធឡើងក្នុងអំឡុងឆ្នាំ២៥០មុនគ្រឹស្តសករាជៗ[៥] នៅឆ្នាំបន្ទាប់ពីសង្គាយនានោះ ពុទ្ធសាសនិកទូតដ៏ល្បីឈ្មោះម្នាក់ឈ្មោះ មហិន្ទ បាននាំយកជាតកទាំងនោះទៅកាន់ប្រទេសសៃឡន (ស្រីលង្កា)ៗ ទៅដល់ទីនោះ "សេចក្តីអត្ថាធិប្បាយ" នូវព្រឹត្តិការណ៍កើតឡើងក្នុងជីវិតរបស់ព្រះពុទ្ធដែលនាំឱ្យព្រះអង្គលើកយកជាតកទៅសម្តែង ត្រូវគេបកប្រែទៅជាភាសា "សិង្ហល"[៦] (ភាសាស្រីលង្កា) ហើយត្រូវគេបកប្រែមកជាភាសាបាលីវិញនៅអំឡុងឆ្នាំ៤៣០នៃគ្រឹស្តសករាជ ដោយព្រះពុទ្ធឃោសាៗ[៧] ប៉ុន្តែ អត្ថបទរឿងជាតកនៅរក្សាជាភាសាដើម ពោលគឺភាសាបាលីតាំងពីដើមរៀងមកៗ[៨] រឿងជាតកត្រូវគេស្គាល់ថាជាអក្សរសាស្ត្រពុទ្ធសាសនា ដែលការអះអាងនេះគឺសម្អាងលើកស្តុតាងនៃសាច់រឿងជាតកឆ្លាក់នៅលើចេតិយសានធិ, អមរវតី និងភារហុតក្នុងស្រុកឥណ្ឌាដែលចម្លាក់ខ្លះមានទាំងសរសេរចំណងជើងជាតកនោះផងៗ តាមរយៈចម្លាក់ទាំងនោះបង្ហាញថា រឿងជាតកគឺត្រូវគេស្គាល់ជាទូទៅនៅក្នុងអំឡុងស.វ.ទី៣មុនគ្រឹស្តសករាជដែល

---

[៥] Rhys Davids 1880: i.

[៦] Rhys Davids 1880: ii.

[៧] Cowell 2005: xxiv.

[៨] Rhys Davids 1880: ii.

ពេលនោះត្រូវគេចាត់ទុកថាជារឿងពិសិដ្ឋ ឬរឿងសក្ការរបស់ពុទ្ធសាសនា។[៩] មិនតែប៉ុណ្ណោះ នៅរវាងពាក់កណ្តាលស.វ.ទី៨នៃគ្រឹស្តសករាជ ជាតកបានផ្សាយចូលទៅតំបន់អារ៉ាប់ហើយ ទទួលបានប្រជាប្រិយភាពយ៉ាងខ្លាំង។ នៅពេលដែលអារ៉ាប់មានទំនាក់ទំនងជាមួយពួកអឺរ៉ុប ពួកគេក៏នាំរឿងនេះទៅកាន់អឺរ៉ុប ហើយមិនយូរប៉ុន្មាន ត្រូវគេបកប្រែទៅជាភាសាអឺរ៉ុប។ ម្ល៉ោះហើយ រឿងព្រេងនិទានរបស់អឺរ៉ុបក៏ទទួលឥទ្ធិពលពីជាតកនេះដែរ។[១០]

នៅរវាងដើមគ្រឹស្តសករាជ អារ្យធម៌ឥណ្ឌាបានផ្សព្វផ្សាយចូលមកតំបន់អាស៊ីអាគ្នេយ៍ ហើយប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដំបូងៗដែលជ្រួតជ្រាបអារ្យធម៌ឥណ្ឌា។ ដោយសារឥទ្ធិពលឥណ្ឌានេះហើយ ទើបប្រទេសកម្ពុជានាពេលនោះគោរពប្រតិបត្តិទាំងព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា (ទាំងហីនយាននិងមហាយាន) តែសាសនាផ្លូវការនាពេលនោះ គឺព្រហ្មញ្ញសាសនា។ តឹកតាងនៃការគោរពព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនានោះ គឺបង្ហាញតាមរយៈប្រតិមា ដែលរកឃើញនៅស្រុកអង្គរបុរី ខេត្តតាកែវ ដែលកាលនោះជារាជធានី និងមណ្ឌលសាសនាយ៉ាងសំខាន់។ ប្រតិមាព្រហ្មញ្ញសាសនាមានដូចជាលិង្គ, ព្រះនារាយណ៍, ព្រះរាមជាដើម។ ចំណែកឯប្រតិមាព្រះពុទ្ធសាសនាមានព្រះពុទ្ធរូបនៅវត្តរំលក ដែលមានអាយុកាលចាស់ជាងគេ (ស.វ.ទី៦-៧?)។ ជាធម្មតា កាលណាសាសនាហូរចូលមក តែងតែនាំគម្ពីរមកជាមួយ។ ដូច្នេះតាមរយៈព្រះពុទ្ធសាសនានេះហើយ ដែលខ្មែរស្គាល់គម្ពីរពុទ្ធសាសនាផ្សេងៗ ជាពិសេសគម្ពីរព្រះត្រៃបិដក។[១១]

ដូចពោលពីខាងលើរួចមកហើយថា សាសនាផ្លូវការដែលព្រះមហាក្សត្រគោរពគឺ ព្រហ្មញ្ញសាសនា។[១២] លើកលែងតែនៅពាក់កណ្តាលស.វ.ទី១២ ដែលព្រះបាទ ធរណីន្ទ្រវរ្ម័នទី២ ជាមហាក្សត្រដំបូងគេដែលកាន់ព្រះពុទ្ធសាសនា ហើយក្រោយមកក្នុងចុងស.វ.ទី១២ ព្រះរាជបុត្ររបស់

---

[៩] Cowell 2005: xxii.

[១០] Cowell 2005: xxx.

[១១] ព្រះត្រៃបិដកកាលនោះមិនមែនជាព្រះត្រៃបិដកដែលយើងស្គាល់សព្វថ្ងៃនេះទេ ប្រហែលព្រះត្រៃបិដកប្រើភាសាសំស្ក្រឹតជាយាន។

[១២] ត្បិតតែដូច្នោះក៏ដោយ ក៏ពុទ្ធសាសនាត្រូវគេគោរពប្រតិបត្តិជាប់រហូតមកមិនមានរង្គោះរង្គើឡើយ ហើយតំបន់ខ្លះអាចមានការនិយមខ្លាំងផង។

អត្ថបទដោយ៖ សាន ផល្លា

ព្រះអង្គ គឺព្រះបាទ ជ័យវរ្ម័នទី៧ ក៏លើកតម្កើងព្រះពុទ្ធសាសនាមហាយានជាសាសនាផ្លូវការរបស់ចក្រភពទាំងមូល។[១៣] ម៉្យោះហើយ ពុំមានអ្វីគួរឱ្យឆ្ងល់ឡើយ ដែលប្រាសាទភាគច្រើនឆ្លាក់រឿងរ៉ាវទាក់ទងនឹងព្រហ្មញ្ញសាសនា។ ប៉ុន្តែ អ្វីគួរឱ្យចាប់អារម្មណ៍នោះគឺមានប្រាសាទព្រហ្មញ្ញសាសនាមួយចំនួនដែលឧទ្ទិសចំពោះព្រះនារាយណ៍ មានឆ្លាក់រឿងជាតក[១៤]ដែរ។ ឧទាហរណ៍ដូចជាប្រាសាទបន្ទាយសម្រែ (ស.វ.ទី១២), ប្រាសាទធម្មនន្ទ (ពាក់កណ្ដាលស.វ.ទី១២), ប្រាសាទចៅសាយទេវតា (ពាក់កណ្ដាលស.វ.ទី១២), ប្រាសាទបេងមាលា (ស.វ.ទី១២) ជាដើម មានដកស្រង់យកឈុតមួយចំនួនក្នុង "ព្រះវេស្សន្តរជាតក" (លេខរៀង៥៤៧) មកឆ្លាក់។ កាលដែលយករឿងពុទ្ធសាសនាទៅឆ្លាក់លើប្រាសាទព្រហ្មញ្ញសាសនាបែបនេះបង្ហាញឱ្យឃើញថា សង្គមខ្មែរពុំមានប្រកាន់និន្នាការសាសនាដាច់ណាត់ហួសហេតុនោះឡើយ ពោលគឺអាចរស់នៅជាមួយគ្នាដោយសុខដុមរមនា។ ផ្ទុត់គំនិតសន្ដោសនិងគោរពគ្នាទៅវិញទៅមកក្នុងជំនឿសាសនាផ្សេងគ្នានេះជាលក្ខណៈនៃអារ្យធម៌ខ្មែរដែលមានរឿងមករហូតដល់បច្ចុប្បន្ន។[១៥] ក្រៅពីនេះ មានប្រាសាទពុទ្ធសាសនាដែលឆ្លាក់រឿងជាតកដូចជា៖ "សិលានិសង្ឃជាតក" (លេខរៀង១៩០) មានឆ្លាក់នៅប្រាសាទព្រះខ័ន និងប្រាសាទតានៃ (រូបលេខ២១)។ "តេមិយ ឬ មូគបក្ខជាតក" (៥៣៨) បង្ហាញនៅលើចម្លាក់ប្រាសាទបាយ័ន។ "មហាជនកជាតក (៥៣៩) មាននៅប្រាសាទបាយ័ន និងនាគព័ន្ធ (រូបលេខ២២)។ "សុវណ្ណសាម ឬសាមជាតក" (៥៤០) មានឆ្លាក់នៅប្រាសាទបាយ័ន (រូបលេខ២៣)។ "ភូរិទត្តជាតក" (៥៤៣) បង្ហាញនៅប្រាសាទតាព្រហ្ម, បន្ទាយក្ដី និងព្រះខ័ន។ "មហានារទកស្សប ឬនារទព្រហ្មជាតក" (៥៤៥) ឆ្លាក់នៅប្រាសាទបាយ័ន។ "វិធុរ ឬវិធូរបណ្ឌិតជាតក" (៥៤៦) មាននៅប្រាសាទបាយ័ន។ ប្រាសាទពុទ្ធសាសនាទាំងអស់នេះសុទ្ធសាងក្នុងអំឡុងចុងស.វ.ទី១២ និងស.វ.ទី១៣ ពោលគឺក្នុងរាជ្យព្រះបាទជ័យវរ្ម័នទី៧។ ចំណែកឯ "ព្រះវេស្សន្តរជាតក" គឺមានឆ្លាក់

---

[១៣] អាំង ជូលាន, អេរិក ប្រេណូវិត្ស, អាស៊ី ថមសុន ១៩៩៨: ៥៨-៦០។

[១៤] ចម្លាក់ជាតកដែលនឹងលើកមកបង្ហាញនៅទីនេះ គឺសំដៅចំពោះតែជាតកទាំងឡាយដែលស្ថិតក្នុងបញ្ជីជាតក ៥៤៧នេះប៉ុណ្ណោះ។

[១៥] អាំង ជូលាន, អេរិក ប្រេណូវិត្ស, អាស៊ី ថមសុន ១៩៩៨: ៥៥។

អត្ថបទដោយ៖ សាន ផល្លា

នៅប្រាសាទព្រះបាលីល័យ (ស.វ.ទី១២/១៣) ព្រមទាំងប្រាសាទព្រហ្មញ្ញសាសនា និងប្រាសាទពុទ្ធសាសនាទាំងអស់ដែលរៀបរាប់ពីខាងលើ។[១៦]

គួរឱ្យចាប់អារម្មណ៍ថា នៅក្នុងចម្លាក់សម័យបុរាណ ក្រៅពី "សិលានិសង្សជាតក" គឺមានតែ "ទសជាតក"[១៧] ពោលគឺជាតិចុងក្រោយទាំង១០នៃព្រះពោធិសត្វ ត្រូវគេដកស្រង់យកទៅឆ្លាក់។ ក្នុងចំណោមទសជាតកនេះទៀតសោត គឺព្រះវេស្សន្តរជាតកទទួលបានការរាប់អានខ្លាំងជាងគេ មិនថាសាសនាព្រហ្មញ្ញ ឬព្រះពុទ្ធ ត្បិតមានឈុតឆាកជាច្រើនត្រូវគេដកស្រង់យកទៅឆ្លាក់នៅតាមប្រាសាទទាំងព្រហ្មញ្ញ និងពុទ្ធសាសនា។ បើយកឈុតឆាកទាំងអស់ដែលគេឆ្លាក់នៅតាមប្រាសាទទាំងនោះមករៀបតាមលំដាប់លំដោយនៃសាច់រឿងឃើញថា សាច់រឿងព្រះវេស្សន្តរស្ទើរតែទាំង១៣កណ្ឌ ដែលរៀបរាប់នៅក្នុងគម្ពីរមហាជាតក៍ ត្រូវគេយកទៅឆ្លាក់ (រូបលេខ៤-៥)។ ប៉ុន្តែ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺក្នុងចំណោមឈុតទាំងអស់នេះ គឺឈុត "ព្រះវេស្សន្តរប្រទានរាជកុមារទាំងពីរទៅតាជូជក" ត្រូវគេយកមកឆ្លាក់ច្រើនជាងគេទាំងនៅប្រាសាទព្រហ្មញ្ញ និងពុទ្ធសាសនា។ ចម្លាក់នេះប្រហែលជាចង់បង្ហាញពីទឹកព្រះទ័យព្រះមហាក្សត្រ ដែលលុះដោយទសពិធរាជធម៌ ពោលគឺកសាងនូវបារមី ពិសេសគឺ "ទានបារមី"។

នៅរវាងស.វ.ទី១៤ ព្រះពុទ្ធសាសនាថេរវាទបានជ្រាបចូលមករហូតចាក់គ្រឹះយ៉ាងមាំក្នុងសង្គមខ្មែរ។ ប្រហែលដោយសារមនោគមថេរវាទនេះហើយ ទើបបានជាសំណង់សម្រាប់ធ្វើកិច្ចប្រតិបត្តិក្នុងពិធីសាសនាត្រូវផ្លាស់ប្តូរពីប្រាសាទទៅជាព្រះវិហារវិញ។ ចំណែករឿងរ៉ាវក្នុងគម្ពីរសាសនាដែលធ្លាប់តែឆ្លាក់ ក៏ប្រហែលជាប្តូរមកគូរវិញដែរ។ មកទល់នឹងពេលនេះ ទសជាតកនៅតែជារឿងដ៏ពេញនិយមសម្រាប់គំនូរនៅតាមវត្ត (រូបលេខ៦)។ ឈុតមួយចំនួនធំពិសេស

---

[១៦] សូមអានលម្អិតអំពីចម្លាក់ជាតកនៅតាមប្រាសាទបុរាណក្នុងសៀវភៅ៖ Roveda 2005: 248-259 និងទៀវ វិចិត្រ ២០១១។

[១៧] ជាតកចុងក្រោយទាំង១០នោះមាន៖ តេមិយជាតក, មហាជនកជាតក, សុវណ្ណសាម ឬសាមជាតក, នេមិរាជឬនេមិជាតក, មហោសថ ឬមហាឧម្មគ្គជាតក, ភូរិទត្តជាតក, ចន្ទកុមារ ឬខណ្ឌហាលជាតក, មហានារទកស្សប ឬនារទព្រហ្មជាតក, វិធុរ ឬវិធូរបណ្ឌិតជាតក និងវេស្សន្តរជាតក។ បើគិតតាមលេខរឿង ទសជាតកនេះមានលេខរឿងចាប់ពី៥៣៨ដល់៥៤៧។ ប្រហែលដោយសាររឿងទាំង១០នេះមានការនិយមខ្លាំងជាងគេ ទើបគេយកជាតកទាំង១០នេះ មកចងក្រងជាគម្ពីរ ឬសៀវភៅមួយដាច់ដោយឡែក ដោយដាក់ចំណងជើងថា "ទសជាតក" ឬ "ទសជាតក៍"។ ម៉្លោះហើយ រឿងទាំង១០ក្នុងទសជាតក ត្រូវគេដាក់លេខរឿងពីលេខ១ដល់លេខ១០វិញ។

អត្ថបទដោយ៖ សាន ផល្លា

ព្រះវេស្សន្តរជាតក ដែលធ្លាប់ឃើញឆ្លាក់នៅតាមប្រាសាទ បានបន្តជីវិតមកដល់គំនូរនៅតាមវត្ត ហើយក្លាយជាប្រពៃណី សម្រាប់ការដកស្រង់យកឈុតទសជាតកមកគូរនៅតាមវត្តមកដល់សព្វថ្ងៃ (រូបលេខ៧)។[១៨] មិនត្រឹមតែប៉ុណ្ណោះ ចម្លាក់ដែលពោលមកនេះក៏ប្រហែលជាជះឥទ្ធិពលទៅលើគំនូរប្រទេសជិតខាងថែមទៀត ទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី។ ម្ល៉ោះហើយ បានជាយើងសង្កេតឃើញថា គំនូរទសជាតកស្ទើរតែដូចគ្នានៅគ្រប់វត្តមិនថានៅស្រុកខ្មែរ, សៀម និងលាវនោះទេ។ ដូចសម័យបុរាណដែរ ក្រៅពីទសជាតក យើងសង្កេតឃើញមានជាតកដទៃទៀតបី-បួនប៉ុណ្ណោះដែលគេលើកយកមកគូរដូចជាៈ ទេវធម្មជាតក (រឿងទី៦), កុលាវកជាតក (រឿងទី៣១), សសបណ្ឌិតជាតក (រឿងទី៣១៦) (រូបលេខ៨)និងឧម្មាទន្តីជាតក (រឿងទី៥២៧)។

ទសជាតកមានប្រជាប្រិយភាពជាងគេបំផុត មិនថានៅស្រុកខ្មែរ, លាវ, សៀម ឬភូមាឡើយ។ ម្ល៉ោះហើយ មិនមានអ្វីគួរឱ្យឆ្ងល់ឡើយ ដែលទសជាតកត្រូវគេដកស្រង់យកទៅឆ្លាក់ ឬគូរនៅតាមទីសក្ការៈនានា។ លើសពីនេះទៅទៀត ព្រះវេស្សន្តរជាតក គឺជារឿងចុងក្រោយបង្អស់ រឹតតែល្បីល្បាញខ្លាំងក្នុងចំណោមអ្នកកាន់ពុទ្ធសាសនានៅអាស៊ីអាគ្នេយ៍ រហូតដល់មានពិធីបុណ្យមួយដែលនៅស្រុកខ្មែរហៅថា "ទេសន៍មហាជាតក៍"។ នៅស្រុកលាវក៏មានពិធីបុណ្យនេះដែរ គ្រាន់តែតាមសម្ដីលាវថា "ប៊ុនផៈវេត"។ ចំណែកនៅស្រុកសៀមហៅ "ថេតមហាឆាត" តែនៅសៀមភាគឦសានគេច្រើនហៅ "ប៊ុនផៈវេត"ដូចនៅស្រុកលាវដែរ ដោយសារមានជនជាតិលាវច្រើនរស់នៅទីនោះ។ ក្នុងពិធីបុណ្យនេះ ព្រះសង្ឃលើកយកព្រះវេស្សន្តរជាតកមកទេសន៍ឱ្យអ្នកស្រុកស្ដាប់។ ពិធីបុណ្យនេះពុំមែនសម្រាប់តែសាសនាប៉ុណ្ណោះទេ តែជាពិធីសម្រាប់សង្គមទាំងមូល ព្រោះប្រារព្ធឡើងដើម្បីសូមឱ្យមានសេចក្ដីសុខដល់ស្រុកទេស ពិសេសឱ្យមានភ្លៀងធ្លាក់គ្រប់គ្រាន់។ ពិធីនោះតែងមានព្រះសង្ឃ និងអ្នកស្រុកពីទីកន្លែងផ្សេងៗមកចូលរួមយ៉ាងច្រើនកុះករ៕

[១៨] សូមអាន សាន ផល្លា ២០០៧។

# ឯកសារពិគ្រោះ


ទៀវ វិចិត្រ

២០១១. ចម្លាក់រឿងជាតកនៅប្រាសាទបុរាណខ្មែរ, នគរវត្ត, ភ្នំពេញ។

សាន ផល្លា

២០០៧. គំនូរនៅតាមវត្ត, វៃយំ, ភ្នំពេញ។

អាំង ជូលាន, អេរិក ប្រេណូវិត្ស, អាស៊ី ថមសុន

១៩៩៨. អង្គរ៖ អតីតបច្ចុប្បន្នអនាគត, អាជ្ញាធរអប្សរា, ភ្នំពេញ។

Cowell, E. B.

2005. *The Jātaka or Stories of the Buddha's Former Births*, Vol. I-II, Motilal Banarsidass Publishers Private Limited, Delhi, 2005.

Horner, I. B.

1993. *Ten Jātaka Stories*, Mahāmakut Rājavidyālaya Press, Bangkok.

Rhys Davids, T. W.

1880. *Buddhist Birth Stories or Jātaka Tales*, Trubner & Co. Ludgate Hill, London.

Roveda, Vittorio.

2005. *Images of the Gods*, River Book, Bangkok.




រូបលេខ១៖ ព្រះពោធិសត្វសង្គ្រោះអ្នកលិចសំពៅក្នុងសមុទ្រ, «សីលានិសង្សជាតក»,
ចម្លាក់ហោជាងប្រាសាទតានៃ ខេត្តសៀមរាប

អត្ថបទដោយ៖ សាន ផល្លា



*រូបលេខ២៖ មន្ត្រីនគរមិថិលាយកដំរីផ្សងរកអ្នកមានបុណ្យ ហើយដំរីក៏ដើរមករកមហាជនក។ ឃើញដូច្នោះ ពួកមន្ត្រីក៏យាងព្រះពោធិសត្វទៅគ្រងរាជ្យ, «មហាជនកជាតក(?)»។ ចម្លាក់នេះក៏ប្រហែលអាចជា «តេមិយជាតក(?)» ដែរ ពោលគឺព្រះរាជាសាកល្បងព្រះតេមិយ ដោយឲ្យដំរីចុះព្រេងមកព្រួចព្រះពោធិសត្វ តែដំរីនោះបែរជាបោលគេច មិនហ៊ានមកក្បែរ, ចម្លាក់ហោជាងប្រាសាទបាយ័ន ខេត្តសៀមរាប។*



*រូបលេខ៣៖ ព្រះបាទ បិលយក្ស តម្រង់ធ្នូបាញ់សត្វព្រៃ តែបែរជាត្រូវសុវណ្ណសាមទៅវិញ។ ឪពុកម្តាយព្រះពោធិសត្វយំឱបកូន (រូបក្រោម), សុវណ្ណសាម និងមាតាបិតាបានកើតនៅព្រហ្មលោក(?) (រូបលើ), «សុវណ្ណសាមជាតក», ចម្លាក់ហោជាងប្រាសាទបាយ័ន ខេត្តសៀមរាប។*

*អត្ថបទដោយ៖ សាន ផល្លា*



រូបលេខ២៨៖ ព្រះវេស្សន្តរដាក់ទានដំរី (រូបឆ្វេង), ដាក់ទានរាជបុត្រ (រូបកណ្ដាល), ដាក់ទានមហេសី (រូបស្ដាំ), «វេស្សន្តរជាតក», ចម្លាក់រចនាបទបាយ័ន ចុងស.វ.ទី១២ ដើមស.វ.ទី១៣ តម្កល់នៅសារមន្ទីរជាតិភ្នំពេញ (រូបថត៖ ជា សុជាតិ)



រូបលេខ២៩៖ ដង្ហែព្រះវេស្សន្តរវិលចូលនគរវិញ (រូបក្រោម), ព្រះវេស្សន្តរជួបជុំគ្រួសារ និងរូបព្រះពុទ្ធនៅកណ្ដាលប្រហែលជាតំណាងឲ្យការត្រាស់ដឹងរបស់ព្រះពោធិសត្វក្នុងអនាគតជាតិ(?) (រូបលើ), «វេស្សន្តរជាតក», ចម្លាក់ហោជាងប្រាសាទបាលីល័យ ខេត្តសៀមរាប។

អត្ថបទដោយ៖ សាន ផល្លា




រូបលេខ២៦៖ សុវណ្ណសាមត្រូវព្រួញរបស់បិលយក្ស, «សុវណ្ណសាមជាតក»,
គំនូរក្នុងសាលាឆាន់វត្តព្រះពុទ្ធអណ្តែត ខេត្តកណ្តាល។



រូបលេខ២៧៖ ជូជកសុំរាជបុត្រពីព្រះវេស្សន្តរ, «វេស្សន្តរជាតក», គំនូរក្នុងវិហារវត្តសានគរ ខេត្តកំពង់ធំ។

អត្ថបទដោយ៖ សាន ផល្លា



រូបលេខ៨៖ ព្រះពោធិសត្វយកកំណើតជាសត្វទន្សាយ ដាក់ទានសាច់ព្រះអង្គឲ្យទៅព្រះឥន្ទ្រ
ដែលកាឡាខ្លួនជាព្រាហ្មណ៍មកល្បងព្រះពោធិសត្វ, «សសបណ្ឌិតជាតក»,
គំនូរក្នុងវិហារវត្តព្រែកតូច ខេត្តកណ្ដាល។

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ សាន ផល្លា